ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 29-Aug-2014, 15:38
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour supreme

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007/ECCC/SC

នៅចំពោះមុខ៖
ចៅក្រម គង់ ស្រ៊ីម ប្រធាន
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Agniezska KLONOWIECKAMILART
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Florence Ndepele Mwachande MUMBA
ចៅក្រម យ៉ា ណារិន

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១៤
ភាសាដើម៖ ខ្មែរ/អង់គ្លេស
ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ

# សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំពន្យារពេល និងបន្ថែមចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណានៃបណ្តឹងសាទុក្ខ

**សហព្រះរាជអាជ្ញា**

**សហមេធាវីជនជាប់ចោទ នួន ជា**

ជា លាង

Nicholas KOUMJIAN

**ជនជាប់ចោទ**

ខៀវ សំផន

នួន ជា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Marie GUIRAUD

សុន អរុណ

Victor KOPPE

**សហមេធាវីជនជាប់ចោទ ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ

Arthur VERCKEN

1. **អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យចន្លោះពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ៦ ខែមករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" និង"អ.វ.ត.ក") បានទទួលសំណើរបស់មេធាវីការពារក្តីរបស់ នួន ជា និង ខៀវ សំផន (ជារួមហៅថា "មេធាវីការពារក្តី") ដែលបានដាក់នៅថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០១៤ សុំពន្យារពេល និងបន្ថែមចំនួនទំព័រ ក្នុងការដាក់សេចក្តីជូនដំណឹងលើបណ្តឹងសាទុក្ខ និងសារណាបណ្តឹងសាទុក្ខ ("សំណើសុំ")[1]។ សហព្រះរាជអាជ្ញា បានដាក់សារណាតបទៅនឹងសំណើនេះ នៅថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០១៤ ("សារណាតប")[2]។ មេធាវីការពារក្តី បានដាក់ចម្លើយតបទៅនឹងសារណាតបនៅថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០១៤ ("ចម្លើយតប")[3]។

2. នៅថ្ងៃទី ៧ ខែសីហា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូង បានចេញសាលក្រមក្នុងសំណុំរឿង ០០២/០១[4] ដោយបានដាក់ពិរុទ្ធភាពលើ ខៀវ សំផន និង នួន ជា ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល(រួមបញ្ចូលអំពើមនុស្សឃាត), ការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀត (រួមបញ្ចូល ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ និងការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស) ហើយបានសម្រេចប្រកាសទោសដាក់ពន្ធនាគារ ម្នាក់ៗអស់មួយជីវិត[5]។

3. មេធាវីការពារក្តីមានបំណងប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនេះ[6] ប៉ុន្តែបានស្នើថា កាលបរិច្ឆេទ និងចំនួនទំព័រដែលកំណត់នៅក្នុងវិធានផ្ទៃក្នុង[7] និងក្នុងសេចក្តីណែនាំអនុវត្ត[8] ពុំមានលក្ខណៈគ្រប់គ្រាន់ល្មម

---

[1] សំណើបន្ទាប់របស់មេធាវីការពារក្តី ខៀវ សំផន និងមេធាវីការពារក្តី នួន ជា សុំពន្យារពេលកំណត់ និងបង្កើនចំនួនទំព័រនៃបណ្តឹងសាទុក្ខ ឯកសារលេខ F3 ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤។

[2] សារណាតបរបស់សហព្រះរាជអាជ្ញា ទៅនឹងមេធាវីការពារក្តី ខៀវ សំផន និងមេធាវីការពារក្តី នួន ជា សុំពន្យារកាលបរិច្ឆេទ និងបន្ថែមចំនួនទំព័រ ទាក់ទងនឹង សំណុំរឿង ០០២/០១ បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ឯកសារលេខ F3/1, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០១៤។

[3] ចម្លើយតបទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញា តបទៅនឹងសំណើសុំរបស់មេធាវីការពារក្តី ខៀវ សំផន និងនួន ជា សុំពន្យារកាលបរិច្ឆេទ និងបន្ថែមចំនួនទំព័រ ទាក់ទងនឹងសំណុំរឿង ០០១/០១ បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ឯកសារលេខ F3/2 ថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០១៤។

[4] សាលក្រមសំណុំរឿង ០០២/០១ ឯកសារលេខ E313 ថ្ងៃទី ៧ ខែសីហា ឆ្នាំ ២០១៤ ("សាលក្រមអង្គជំនុំជម្រះសាលាដំបូង")។

[5] សាលក្រមអង្គជំនុំជម្រះសាលាដំបូងទំព័រ ៩៧៨។

[6] សំណើសុំ កថាខណ្ឌ ២។

នឹងអនុញ្ញាតឱ្យធ្វើបណ្តឹងសាទុក្ខមួយមានអត្ថន័យពេញលេញក្នុងរឿងក្តីបច្ចុប្បន្ននេះ[9] ដូចនេះ បានពិចារណាឃើញថា សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ តម្រូវឱ្យមានលក្ខណៈល្អិតល្អន់ ដោយហេតុថា ពុំអាចធ្វើការកែប្រែបានបន្ទាប់ពីត្រូវបានដាក់ចូលក្នុងសំណុំរឿងរួចហើយ[10]។ មេធាវីការពារក្តី បានលើកឡើងថា ទំហំ និងភាពស្មុគស្មាញនៃសំណុំរឿង, ចំនួនទំព័រដ៏ច្រើននៃសាលក្រម, បញ្ហាថ្មីៗជាច្រើនដែលរំពឹងថានឹងកើតមានទៅលើបណ្តឹងសាទុក្ខ និងភាពជាក់ស្តែងក្នុងការតម្រូវឱ្យឯកសារត្រូវតែដាក់ជាភាសាខ្មែរ និងភាសាអង់គ្លេស (និង/ឬ) ភាសាបារាំងនោះ គឺជាកាលៈទេសៈពិសេស ដែលជាមូលហេតុក្នុងការសុំការពន្យារពេល និងបន្ថែមចំនួនទំព័រ[11]។

4. អាស្រ័យហេតុនេះ មេធាវីការពារក្តីស្នើសុំថា កាលបរិច្ឆេទ និងការកំណត់ចំនួនទំព័រ ជាធរមានសម្រាប់ការដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ត្រូវពន្យារពេលរហូតដល់ ៧៤ ថ្ងៃ គិតចាប់ពី ការជូនដំណឹងអំពីសាលក្រម និង ៥០ទំព័រជាភាសាអង់គ្លេស ឬភាសាបារាំង ជាមួយនិងភាសាខ្មែរដែលមានចំនួនទំព័រប្រហាក់ប្រហែលគ្នាដែរ[12]។ ដូចគ្នាដែរ មេធាវីការពារក្តីបានស្នើសុំថា កាលបរិច្ឆេទ និងការកំណត់ចំនួនទំព័រជាធរមាន សម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខ ត្រូវពន្យារពេលរហូតដល់ ១១៧ ថ្ងៃ គិតចាប់ពីការដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និង ១៥០ទំព័រ ជាភាសាអង់គ្លេស ឬបារាំង ជាមួយនិងភាសាខ្មែរដែលមានចំនួនទំព័រប្រហាក់ប្រហែលគ្នាផងដែរ[13]។

5. សហព្រះរាជអាជ្ញា ពុំបានជំទាស់ទៅនឹងសំណើសុំបន្ថែមចំនួនទំព័រសម្រាប់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ[14]។ សហព្រះរាជអាជ្ញា ពុំបានជំទាស់ទៅនឹងសំណើសុំការបន្ថែមចំនួនទំព័រលើសារណាបណ្តឹងសាទុក្ខ ផងដែរ ប៉ុន្តែ បានស្នើសុំថា ប្រសិនការកំណត់ចំនួនទំព័រលើសារណាបណ្តឹងសាទុក្ខ ត្រូវបាន

---

[7] វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក វិសោធនកម្មលើកទី ៨ ចុះថ្ងៃទី ៣ ខែសីហា ឆ្នាំ២០១៤ ("វិធានផ្ទៃក្នុង")។

[8] សេចក្តីណែនាំអនុវត្ត ស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក វិសោធនកម្មលើកទី ៨ ថ្ងៃទី ៧ ខែមីនា ឆ្នាំ ២០១២ ("សេចក្តីណែនាំអនុវត្ត")។

[9] សំណើសុំ កថាខណ្ឌ ២, ៩ ដល់ ៣០។

[10] សំណើសុំ កថាខណ្ឌ កថាខណ្ឌ ៩ ដល់ ១៦។

[11] សំណើសុំ កថាខណ្ឌ ១៧ ដល់ ៣០។

[12] សំណើសុំ កថាខណ្ឌ ៣០ និង ៣១។

[13] សំណើសុំ កថាខណ្ឌ ៣០ និង ៣១។

[14] សំណើសុំ កថាខណ្ឌ ៣។

កំណត់បែបណានោះសម្រាប់ក្រុមមេធាវីការពារក្តីនីមួយៗ សារណាតបទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាក៏ត្រូវទទួលបានការអនុញ្ញាតនូវចំនួនទំព័រដូចគ្នាដែរ[15]។ ម្យ៉ាងវិញទៀត ប្រសិនបើ ក្រុមមេធាវីការពារក្តីនីមួយៗ ត្រូវបានអនុញ្ញាតឱ្យចំនួន ១៥០ទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខនោះ សហព្រះរាជអាជ្ញា ស្នើសុំការអនុញ្ញាតចំនួន ៣០០ទំព័រ[16]។ ទាក់ទងនឹងកាលបរិច្ឆេទ សហព្រះរាជអាជ្ញាដាក់សារណាតបថា សំណើសុំពន្យារពេលសម្រាប់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ពុំមានលក្ខណៈចាំបាច់ឡើយ[17]។ ទោះជាយ៉ាងណាក្តី សហព្រះរាជអាជ្ញាបានពិចារណាឃើញថា ការពន្យារពេលសម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខ ត្រូវទទួលបានការអនុញ្ញាត ប៉ុន្តែ បានផ្តល់ជាយោបល់ថា ចំនួន៣០បន្ថែម គឺមានលក្ខណៈគ្រប់គ្រាន់ ដែលជាសរុបមានចំនួន ៩០ថ្ងៃគិតចាប់ពីការដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ[18]។ សហព្រះរាជអាជ្ញាបានបន្ថែមទៀតថា ការអនុញ្ញាតរហូតដល់៩០ថ្ងៃសម្រាប់ ភាគីនីមួយៗក្នុងការដាក់សារណាតប គឺជាការសមហេតុសមផល[19]។

6. នៅក្នុងចម្លើយតបរបស់ខ្លួន មេធាវីការពារក្តីលើកឡើងថា ប្រសិនបើអង្គជំនុំជម្រះសម្រេចតាមសំណើសុំរបស់មេធាវីការពារក្តី ដោយអនុញ្ញាតចំនួន ១៥០ទំព័រ ចំពោះក្រុមនីមួយៗនោះ ដូចនេះ សារណាតបរួមរបស់សហព្រះរាជអាជ្ញា គឺត្រូវកម្រិតត្រឹមតែ ២០០ទំព័រប៉ុណ្ណោះ[20]។ មេធាវីការពារក្តីបានជំទាស់បន្ថែមទៀតនៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំពន្យារពេលសម្រាប់ដាក់សារណាតបរបស់ខ្លួន ឱ្យដូចគ្នាទៅនឹងរយៈពេលនៃសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីដែរ[21]។ បន្ថែមលើនេះ មេធាវីការពារក្តីបានលើកនូវជម្រើសមួយទាក់ទងនឹងការស្នើសុំរយៈពេល៧៤ថ្ងៃ សម្រាប់ការពន្យារពេលដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដោយពន្យារពេលរហូតដល់៦០ថ្ងៃគិតចាប់ពីពេលចេញសាលក្រម ហើយ១៤ថ្ងៃបន្ថែមទៀតសម្រាប់ការបកប្រែ ឬជាជម្រើស ការអនុញ្ញាតដាក់តែមួយភាសា[22]។

---

15 សារណាតប កថាខណ្ឌ ៤។

16 សារណាតប កថាខណ្ឌ ៤។

17 សារណាតប កថាខណ្ឌ ៦។

18 សារណាតប កថាខណ្ឌ ៦។

19 សារណាតប កថាខណ្ឌ ៦។

20 ចម្លើយតប កថាខណ្ឌ ២។

21 ចម្លើយតប កថាខណ្ឌ ៣។

22 ចម្លើយតប កថាខណ្ឌ ៥ និង ៦ (គ)។

7. វិធាន ១០៥(៣)នៃវិធានផ្ទៃក្នុងចែងថា "ភាគីដែលមានបំណងប្តឹងសាទុក្ខចំពោះសាលក្រម ត្រូវដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដោយបញ្ជាក់អំពីមូលដ្ឋាននៃបណ្តឹងសាទុក្ខនោះ" និងថា "បន្ទាប់មក ម្ចាស់បណ្តឹងសាទុក្ខ ត្រូវដាក់សារណាបណ្តឹងសាទុក្ខដោយបញ្ជាក់ពីទឡ្ហីករណ៍ និងឯកសារសំអាងផ្លូវច្បាប់ដែលគាំទ្រមូលដ្ឋាននីមួយៗ"។ វិធាន ១០៧(៤) នៃវិធានផ្ទៃក្នុង បញ្ជាក់ថា សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ត្រូវដាក់ក្នុងរយៈពេល៣០ថ្ងៃគិតចាប់ពីថ្ងៃប្រកាសសាលក្រម និងថា សារណាបណ្តឹងសាទុក្ខបន្តបន្ទាប់ ត្រូវដាក់ក្នុងរយៈពេល៦០ថ្ងៃគិតចាប់ពីថ្ងៃដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ។ យោងទៅលើមាត្រា ៥.២ នៃសេចក្តីណែនាំអនុវត្ត ឯកសារដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល មិនត្រូវលើសពី៣០ទំព័រ ជាភាសាអង់គ្លេស ឬភាសាបារាំង ឬ៦០ទំព័រជាភាសាខ្មែរឡើយ។ វិធាន ៣៩(២) នៃវិធានផ្ទៃក្នុងចែងថា លើកលែងតែមានចែងផ្សេងពីនេះនៅក្នុងវិធានផ្ទៃក្នុង ចៅក្រមអាចកំណត់ពេលវេលាសម្រាប់ដាក់សារណា សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងឯកសារពាក់ព័ន្ធទៅនឹងសំណើសុំណាមួយ ឬបណ្តឹងឧទ្ធរណ៍។ វិធាន៣៩(៤)នៃវិធានផ្ទៃក្នុង ក៏បានផ្តល់អំណាចផងដែរដល់ចៅក្រម "ធ្វើការពន្យារកាលបរិច្ឆេទ ដែលខ្លួនបានកំណត់" ឬ"ទទួលស្គាល់នូវសុពលភាពនៃកិច្ចទាំងឡាយណាដែលបានធ្វើ ក្រោយពីពេលកំណត់ដែលបានចែងក្នុងវិធាននេះ(វិធានផ្ទៃក្នុង) ត្រូវបានផុតរលត់ ប្រសិនបើខ្លួនយល់ឃើញថាត្រឹមត្រូវសមហេតុផល"[23]។

8. ទាក់ទងនឹងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា ៧៤ថ្ងៃ និង៥០ទំព័រ ដែលបានស្នើឡើងដោយ មេធាវីការពារក្តី ពុំមានលក្ខណៈចាំបាច់នោះឡើយ។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ គឺកម្រិតត្រឹមតែការបញ្ជាក់ ឬគ្រាន់តែពន្យល់ត្រួសៗ អំពីការលើកឡើងនូវកំហុសអង្គច្បាប់ដែលធ្វើឱ្យសេចក្តីសម្រេចនេះមោឃៈ និងការលើកឡើងនូវកំហុសអង្គហេតុដែលបណ្តាលឱ្យមានភាពអយុត្តិធម៌ ហើយពុំតម្រូវឱ្យមានការលើកឡើងនូវទឡ្ហីករណ៍ ឬសំអាងផ្លូវច្បាប់នានា ដើម្បីគាំទ្រឡើយ[24]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ទឡ្ហីករណ៍នេះ អាចរួមបញ្ចូល ផងដែរនូវសេចក្តីសម្រេចនានារបស់អង្គជំនុំជម្រះសាលាដំបូង ដែលពុំតម្រូវឱ្យធ្វើបណ្តឹងសាទុក្ខភ្លាមៗ ក្នុងពេលកិច្ចដំណើរការនីតិវិធីជំនុំជម្រះ និងថា "សេចក្តីសម្រេចនេះ អនុញ្ញាតឱ្យប្តឹងតែក្នុងពេលដំណាលគ្នាជាមួយសាលក្រមលើអង្គសេចក្តីតែប៉ុណ្ណោះ"[25]។ ទោះជាយ៉ាងណាក្តី នៅក្នុងពេលនេះ ទឡ្ហីករណ៍ទាំង នេះ តម្រូវ

---

[23] *សូមមើលផងដែរ* មាត្រា ៨.១ នៃសេចក្តីណែនាំអនុវត្ត។

[24] វិធាន ១០៥(៣) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* វិធាន១០៤(១) នៃវិធានផ្ទៃក្នុង។

[25] វិធាន ១០៤(៤)នៃវិធានផ្ទៃក្នុង។

ត្រឹមតែបញ្ជាក់ពីកំហុសដែលបានចោទប្រកាន់ប៉ុណ្ណោះ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា មេធាវីការពារក្ដីពុំបានបង្ហាញនូវមូលហេតុត្រឹមត្រូវសម្រាប់ការសុំបន្ថែមលើចំនួនទំព័រដែលបានកំណត់ចំនួន៣០ទំព័រ សម្រាប់ការដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ។

9. ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ចំនួនទំព័រដ៏ច្រើននៃសាលក្រម (៦២៣ ទំព័រជាភាសាអង់គ្លេស, ៧៧៧ ទំព័រជាភាសាបារាំង និង ៩៨១ទំព័រជាភាសាខ្មែរ) តម្រូវឱ្យមានពេលវេលាបន្ថែម ក្នុងការអានឱ្យបានហ្មត់ចត់ និងពិភាក្សាលើខ្លឹមសារនៅក្នុងក្រុមមេធាវីការពារក្ដី និងជាមួយជនជាប់ចោទ។ ទីបញ្ចប់ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការពន្យារពេលប្រហាក់ប្រហែលគ្នាសម្រាប់ការចេញសេចក្ដីសម្រេចរបស់ខ្លួនលើបញ្ហាបច្ចុប្បន្ននេះ គឺមានលក្ខណៈសមស្រប។ ដូច្នេះ សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ មិនត្រូវដាក់ឱ្យលើសពី៣០ថ្ងៃ បន្ទាប់ពីការជូនដំណឹងនៃសេចក្ដីសម្រេចនេះ។ ប្រសិនបើ មេធាវីការពារក្ដីស្នើសុំការអនុញ្ញាតដាក់តែមួយភាសា ដោយដាក់ឯកសារបកប្រែតាមក្រោយ មេធាវីការពារក្ដីអាចដាក់សំណើនេះ ក្នុងពេលវេលាសមស្របណាមួយបាន។

10. ទាក់ទងនឹងការដាក់សារណាទាំងអស់ពាក់ព័ន្ធនឹងការពន្យារពេល និងការបន្ថែមចំនួនទំព័រលើសារណាបណ្ដឹងសាទុក្ខ និងសារណាតប អង្គជំនុំជម្រះតុលាការកំពូលពិចារណាអំពីភាពជាក់ស្ដែងឃើញថា ការពន្យារពេល ចាំបាច់ត្រូវបានអនុញ្ញាត ដោយសំអាងលើទំហំ និងភាពស្មុគស្មាញនៃសំណុំរឿង និងសាលក្រម។ ទោះជាយ៉ាងណាក្ដី ក្នុងពេលបច្ចុប្បន្ន ដោយហេតុថា ពុំមានការកំណត់ជាក់ច្បាស់នូវទំហំនៃសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ជាការធ្វើឡើងមុនពេលកំណត់ ក្នុងការសម្រេចពីពេលវេលា និងចំនួនទំព័របន្ថែមដែលតម្រូវនោះ។ ទាក់ទងនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំការអនុញ្ញាតចំនួនទំព័របន្ថែម អង្គជំនុំជម្រះតុលាការកំពូលបដិសេធសំណើសុំនេះចោល ដោយសារកង្វះនូវភស្ដុតាងបញ្ជាក់ច្បាស់លាស់ ហើយពិចារណាឃើញថា មូលហេតុត្រឹមត្រូវ ត្រូវតែបញ្ជាក់នៅក្នុងសំណើនីមួយៗ ទៅលើការបង្ហាញពីអត្ថប្រយោជន៍ផ្លូវច្បាប់ជាក់លាក់របស់ភាគីដែលស្នើសុំ។ ជាពិសេស ការពន្យារពេលដែលស្នើឡើងសម្រាប់ដាក់សារណាបណ្ដឹងសាទុក្ខ ត្រូវស្របគ្នាទៅនឹងទំហំនៃបណ្ដឹងសាទុក្ខរបស់ម្ចាស់បណ្ដឹងសាទុក្ខ ហើយពុំគ្រាន់តែធ្វើការប្រដូចទៅនឹងការពន្យារពេលដែលស្នើឡើងដោយម្ចាស់ប្ដឹងសាទុក្ខដទៃទៀតនោះឡើយ។ ដូចគ្នានេះដែរ ពុំមានការសម្រេចណាទាក់ទងនឹងកាលបរិច្ឆេទ និងចំនួនទំព័រដែលចាំបាច់សម្រាប់សារណាតប ត្រូវបានធ្វើឡើងក្នុងពេលនេះឡើយ។

យោងតាមសំអាងខាងលើ **អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា:**

**ទទួលយក**ផ្នែកខ្លះនៃសំណើ,

**បង្គាប់**ថា រាល់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ត្រូវដាក់ក្នុងរយៈពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងនៃសេចក្តីសម្រេចនេះ,

**ប្រកាស**ថា សេចក្តីសម្រេចបច្ចុប្បន្ន ពុំប៉ះពាល់ដល់សំណើណាមួយនាពេលអនាគតដែលស្នើសុំពន្យារពេល ឬបន្ថែមទំព័រ តាមករណីចាំបាច់ ឬសមស្របឡើយ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១៤

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

E.C.C.C * C.E.T.C

**គង់ ស្រ៊ឹម**